**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...............០២៩/១៦...............ក.ប/ស.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# ការចុះលេខលើបង្កាន់ដៃ និងលិខិតសម្រាប់ប្រើប្រាស់ ក្នុងការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព

ដើម្បីគ្រប់គ្រងការងាររដ្ឋបាលលើផ្នែកចុះលេខបង្កាន់ដៃ និងលិខិតសម្រាប់អនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព ក្រសួងសូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធ និងមន្ត្រីទទួលបន្ទុកទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

## ក. ការចុះលេខបង្កាន់ដៃ និងលិខិត

រាល់ការចុះលេខបង្កាន់ដៃ និងលិខិត ត្រូវអនុវត្តតាមទម្រង់៖ **(លេខរៀង)/(ឆ្នាំ)/(អក្សរកាត់អង្គភាព)/(អក្សរកាត់ឈ្មោះបង្កាន់ដៃ ឬលិខិត)**

- លេខរៀងនៃបង្កាន់ដៃ និងលិខិតនីមួយៗ មាន៤ខ្ទង់ ចាប់ពីលេខ ០០០១ ទៅ៩៩៩៩
- អក្សរកាត់នៃឈ្មោះបង្កាន់ដៃ ឬលិខិតនីមួយៗ ត្រូវកំណត់ ដូចតទៅ៖

| ល.រ | ឈ្មោះបង្កាន់ដៃ និងលិខិត | អក្សរកាត់ |
|---|---|---|
| ១ | បង្កាន់ដៃពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីសហជីព | ប.ព.ស |
| ២ | បង្កាន់ដៃពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការងារ | ប.ព.ក |
| ៣ | បង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជី | ប.ទ.ព |
| ៤ | បង្កាន់ដៃទទួលសំណុំឯកសារ | ប.ទ.ឯ |
| ៥ | បង្កាន់ដៃទទួលលិខិតជូនដំណឹងស្តីពីជនដែលត្រូវទទួលបានការការពារពិសេស | ប.ទ.ក |
| ៦ | លិខិតព្រមានចំពោះអំពើល្មើសនឹងច្បាប់ស្តីពីសហជីព | ល.ព្រ.ស |
| ៧ | លិខិតជូនដំណឹងស្តីពីការពន្យារពេលចុះបញ្ជីសហជីព/សមាគមនិយោជក | ល.ជ.ព |
| ៨ | លិខិតជូនដំណឹងស្តីពីកាតព្វកិច្ចរក្សាបញ្ជិកាសហជីព/សមាគមនិយោជក | ល.ជ.រ |
| ៩ | លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម | ល.ប.វ |

ឧទាហរណ៍

- ការចុះលេខបង្កាន់ដៃពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីសហជីព របស់ក្រុមអធិការកិច្ចការងារទី១៖ **០០០១/១៦/ក.ប/អ.ធ.ក១/ប.ព.ស**
- ការចុះលេខបង្កាន់ដៃទទួលសំណុំឯកសារ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ៖ **០០០១/១៦/មកប/ខសន/ប.ទ.ឯ**



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## ខ. ទីកន្លែងបង់ប្រាក់ពិន័យ

អង្គភាពដែលចេញបង្កាន់ដៃពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីសហជីព ឬ បង្កាន់ដៃពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការងារ ត្រូវបញ្ជាក់នៅក្នុងបង្កាន់ដៃអំពីទីកន្លែងបង់ប្រាក់ពិន័យ ដូចខាងក្រោម៖

- នៅនាយកដ្ឋានអធិការកិច្ចការងារ សម្រាប់ក្រុមអធិការកិច្ចការងារថ្នាក់កណ្តាល
- នៅការិយាល័យអធិការកិច្ច និងវិវាទការងារ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សម្រាប់ក្រុមអធិការកិច្ចការងារថ្នាក់រាជធានី ខេត្ត។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាព និងមន្ត្រីទទួលបន្ទុកទាំងអស់ អនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**